# សេចក្តីប្រកាសជ្រើសរើសបុគ្គលិក

ក្នុងឆ្នាំ២០១៣កន្លងទៅនេះ មូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ត្រូវបានដាក់ឲ្យដំណើរការដែលការគ្រប់គ្រង និងអនុវត្តដោយក្រុមប្រឹក្សា និងរដ្ឋបាលក្រុង ស្រុក។ កត្តានេះតម្រូវឱ្យមានការគាំទ្របច្ចេកទេសលើកិច្ចការមួយចំនួនដូចជា៖ កិច្ចការហិរញ្ញវត្ថុ ការរៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ ការគ្រប់គ្រង ការតាមដាន និងវាយតម្លៃ។ ជាមួយនឹងការគាំទ្រខាងផ្នែកបច្ចេកទេស ការបែងចែក ឬការផ្តល់ធនធានមនុស្សប្រកបដោយសមត្ថភាព និងមានឆន្ទៈបំពេញការងារ និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់រដ្ឋបាលក្រុង ស្រុក ដើម្បីធានាបាននូវការគាំទ្រដ៏មានប្រសិទ្ធិភាពដល់រដ្ឋបាលឃុំ សង្កាត់ ក៏ជាសកម្មភាពបន្ទាន់ពុំអាចខ្វះបានទាំងពេលបច្ចុប្បន្ន និងទៅ អនាគត។

អាស្រ័យហេតុនេះ រដ្ឋបាលខេត្ត **ពោធិ៍សាត់** សូមប្រកាសជ្រើសរើសបេក្ខភាព សម្រាប់មុខតំណែងដូចខាងក្រោម៖

| មុខតំណែង | ចំនួន | ទីកន្លែងបំពេញការងារ | ប្រាក់ខែ |
|---|---|---|---|
| មន្ត្រីព័ត៌មានវិទ្យាថ្នាក់ខេត្ត | ០១ | សាលាខេត្តពោធិ៍សាត់ | ៥៦០ដុល្លា/១ខែ |

តួនាទីនិងភារកិច្ចទទួលខុសត្រូវលម្អិត(TOR) និងតម្រូវការគុណសម្បត្តិសម្រាប់មុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋានគ.ជ.អ.ប(NCDD Job Application Form)អាចរកបាន នៅទីចាត់ការគ្រប់គ្រងធនធានមនុស្ស នៃសាលាខេត្តពោធិ៍សាត់និងមាននៅលើ គេហទំព័រ របស់គ.ជ.អ.ប (http://www.ncdd.gov.kh/procurementjobs) និងមានបិទផ្សាយនៅលើ ក្តារព័ត៌មានសាលា ខេត្តក្រុងស្រុក អង្គការសង្គមស៊ីវិលនិងមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត។

បេក្ខជនបេក្ខនារីដែលមានចំណាប់អារម្មណ៍សូមផ្ញើលិខិតដាក់ពាក្យសុំ(Cover letter)ប្រវត្តិរូប សង្ខេប (CV)និងពាក្យសុំបម្រើការងាររបស់គ.ជ.អ.ប(NCDD Job Application Form)ដោយមានបញ្ជាក់ ព័ត៌មានសម្រាប់ទំនាក់ទំនង (រួមមាន៖អាស័យដ្ឋានលេខទូរស័ព្ទឬអ៊ីម៉ែល) មកកាន់ផ្នែកគ្រប់គ្រងបុគ្គលិកនៃទីចាត់ការគ្រប់គ្រងធនធានមនុស្សនៃសាលាខេត្តពោធិ៍សាត់ នៅគ្រប់ម៉ោងធ្វើការឬតាមរយៈ សារអេឡិចត្រូនិច p.sovann@pur.ncdd.gov.kh ឬតាមរយៈទូរស័ព្ទ ០៩២ ៥២០ ០១០ ឬ កញ្ញា **ឡុង ស៊ីណារ៉េត** អនុប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស ដែលមានលេខទូរស័ព្ទ: ០១២ ៩១៨ ២៥១ ឬលេខ ០៩៧ ៤៧១១០៤៥ រៀងរាល់ម៉ោងធ្វើការ ។

**ស្ត្រីត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យសម្រាប់មុខតំណែងនេះ**

**ថ្ងៃឈប់ទទួលពាក្យ: ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១៧ ។**

**មានតែបេក្ខភាពដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខភាពអាទិភាព (shortlist) ប៉ុណ្ណោះ**

**ដែលនឹងទទួលបានព័ត៌មានអំពីការប្រឡងជ្រើសរើស។**

__**ចំណាំ៖**__

មុខតំណែងនេះជាប្រភេទបុគ្គលិកកិច្ចសន្យា ដូច្នេះបេក្ខភាពដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារ ត្រូវតែមិនមែនជាមន្ត្រីរាជការស៊ីវិល ។ ក្នុងករណីដែលបេក្ខភាពជាមន្ត្រីរាជការស៊ីវិល បេក្ខភាពនោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស ក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ ។

**ពោធិ៍សាត់ ថ្ងៃទី..០៤.. ខែកក្កដា ឆ្នាំ២០១៧**

**សាលាខេត្តពោធិ៍សាត់**